# របាយការណ៍
# បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២៣
# របស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃ និងបញ្ញាញាណដ៏ភ្លឺស្វាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ***ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** ធានាយុត្តិធម៌សង្គម ពង្រឹងប្រសិទ្ធភាពនៃកម្មវិធីកំណែទម្រង់ក្នុងគ្រប់វិស័យទាំងអស់ សម្រាប់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាពនិងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០។

ក្រសួងអភិវឌ្ឍន៍ជនបទ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការងារអភិវឌ្ឍន៍ជនបទ សំដៅជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងបង្រួមគំលាតរវាងទីក្រុង និងជនបទ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា ។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសម្រាប់អនុវត្ត ៥ ឆ្នាំ ២០១៩-២០២៣ ។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដែលជាសេនាធិការផ្ទាល់របស់ក្រសួង បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជនបទក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការងារផែនទីជនបទ ការបង្កើតជាសហគ្រាសលក្ខណគ្រួសារនិងខ្នាតតូចនៅជនបទ កិច្ចការស្វែងរកទីផ្សារសម្រាប់ដោះដូរផលិតផល និងបង្កើតបណ្តាញទំនាក់ទំនងរវាងផលិតករ និងទីផ្សារផលិតផលក្នុងគោលដៅចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ។

## ២. សកម្មភាព និងលទ្ធផលការងារសម្រេចបានឆ្នាំ ២០២២

### ២.១ លទ្ធផលតាមរយៈថវិកាកម្មវិធី

#### ២.១.១ ស្ថានភាពមន្ត្រីរាជការ និងការងារកិច្ចការទូទៅ

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមានមន្ត្រីរាជការសរុបចំនួន ៣៥ នាក់ (ស្រី ១២ នាក់)។

| ល.រ | អង្គភាព | ចំនួនមន្ត្រីរាជការ | | | មុខងារ | | | មន្ត្រីធ្វើការនៅក្រៅ | |
|---|---|---|---|---|---|---|---|---|---|
| | | ប | ស | សរុប | ប្រធាន | អនុប្រធាន | សមាជិក | ប | ស |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ថ្នាក់ដឹកនាំនាយកដ្ឋាន | ៨ | ១ | ៩ | ១ | ៨ | ០ | ០ | ០ |
| ២ | ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ៣ | ៤ | ៧ | ១ | ៣ | ៣ | ០ | ០ |
| ៣ | ការិយាល័យឥណទានជនបទ | ៥ | ៣ | ៨ | ១ | ៤ | ៣ | ០ | ០ |
| ៤ | ការិយាល័យសហគ្រាសខ្នាតតូច | ៦ | ០ | ៦ | ១ | ៤ | ១ | ០ | ០ |
| ៥ | ការិយាល័យរកទីផ្សារ | ១ | ៤ | ៥ | ១ | ៣ | ១ | ០ | ០ |
| **សរុប** | | **២៣** | **១២** | **៣៥** | **៥** | **២២** | **៨** | **០** | **០** |

ក្នុងរយៈពេលមួយឆ្នាំនេះ ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនាយកដ្ឋានបានចូលរួមកម្មវិធីនានាដូចខាងក្រោមៈ

- បានចូលរួមសិក្ខាសាលា ចំនួន ១១ លើក។
- បានចូលរួមកិច្ចប្រជុំពិភាក្សាការងារ ចំនួន ២៣លើក។
- បានចូលរួមក្នុងពិធីបុណ្យជាតិ ចំនួន ៤ លើក ។
- បានចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ៤ លើក។
- បានចូលរួមសំណេះសំណាលជាមួយបងប្អូននារីក្នុងនាយកដ្ឋានក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២២ ចំនួន ១ លើក។
- បានចូលរួមក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។
- បានចូលរួមជួបសំណេះសំណាល និងការចុះសួរសុខទុក្ខនាយទាហាន នាយទាហានរង និងពលទាហាននៃកងពលតូចថ្មើរជើងលេខ ៥២ ស្ថិតក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ចំនួន ២លើក។
- បានចូលរួមពិធីអបអរសាទរសមិទ្ធិផលនៃកិច្ចគាំទ្រលើវិស័យបរិស្ថានរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងការដាក់ឱ្យដំណើរការគម្រោង "USAID មរតកបៃតង" កាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២២ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី។
- បានចូលរួមទិវាអន្តរជាតិជនជាតិភាគតិចពិភពលោកលើកទី ២៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០២២ នៅសាលមហោស្រព ខេត្តក្រចេះ។
- បានចូលរួមទទួលគណៈប្រតិភូជាន់ខ្ពស់ ចំនួន ២ លើក ។
- បានចូលរួមពិធីបើកកីឡាជាតិលើកទី ៣ ឆ្នាំ ២០២២ ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅពហុកីឡាដ្ឋានជាតិមរតកតេជោ។
- បានចូលរួមសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី ៩ ស្តីពីដំណើរឆ្ពោះទៅកាន់ការស្តារឡើងវិញ និងភាពធន់ក្រោយកូវីដ-១៩ កាលពីថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា។

## ២.១.២ ការងារឥណទានជនបទ

**លទ្ធផលការងារឥណទានជនបទនៅតាមបណ្តាខេត្តគោលដៅ**

គិតត្រឹមថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន **៣ ៦៤០ ១៥៩ ៦០០ រៀល** (**បីពាន់ប្រាំមួយរយសែសិបលានមួយរយហាសិបប្រាំបួនពាន់ប្រាំមួយរយរៀល**) **ស្មើនឹង ៩៩៨ ៩៧៣,២៣ ដុល្លារអាមេរិក** (**ប្រាំបួនរយកៅសិបប្រាំបីពាន់ប្រាំបួនរយចិតសិបបីដុល្លារនិងម្ភៃបីសេន**) (១ USD= ៤០០០ រៀល) មានអ្នកខ្ចីសរុបចំនួន ៣ ១៧៦ នាក់ស្រី ចំនួន ២ ៥០៥ នាក់ នៅភូមិគោលដៅចំនួន ១៧៩ ភូមិ ៦៦ ឃុំ ៣០ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥ ដូចខាងក្រោម៖

| ល.រ | ខេត្ត | ឥណទានកំពុងប្រើប្រាស់ដោយអតិថិជន ($) | ចំនួនអ្នកខ្ចី (នាក់) | ស្ត្រី (នាក់) | ចំនួន ភូមិ | ចំនួន ឃុំ | ចំនួន ស្រុក |
|---|---|---|---|---|---|---|---|
| I. **ប្រតិបត្តិករឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | | |
| ១ | កំពង់ចាម | 284,300.00 | 481 | 350 | 22 | 11 | 4 |
| ២ | ត្បូងឃ្មុំ | 35,506.73 | 42 | 32 | 23 | 10 | 4 |
| ៣ | បាត់ដំបង | 14,087.83 | 40 | 26 | 3 | 2 | 2 |
| ៤ | ព្រះសីហនុ | 2,000.00 | 6 | 6 | 1 | 1 | 1 |
| ៥ | តាកែវ | 27,601.03 | 83 | 61 | 14 | 5 | 1 |
| ៦ | កំពង់ស្ពឺ | 4,265.07 | 30 | 27 | 1 | 1 | 1 |
| ៧ | កំពង់ធំ | 2,775.00 | 13 | 12 | 2 | 1 | 1 |
| ៨ | ស្ទឹងត្រែង | 2,775.00 | 16 | 13 | 3 | 3 | 1 |
| ៩ | កំពង់ឆ្នាំង | 6,150.00 | 42 | 31 | 2 | 1 | 1 |
| សរុប (I) | | 379,460.63 | 753 | 558 | 71 | 35 | 16 |
| II. **ការងារឥណទានសហប្រតិបត្តិការជាមួយអង្គការដៃគូ** | | | | | | | |
| ១ | កំពត | 73,580.85 | 212 | 198 | 10 | 6 | 2 |
| ២ | ពោធិ៍សាត់ | 268,725.00 | 922 | 858 | 37 | 12 | 6 |
| ៣ | សៀមរាប | 28,665.00 | 116 | 96 | 2 | 2 | 2 |
| ៤ | កោះកុង | 40,739.75 | 201 | 167 | 10 | 5 | 2 |
| ៥ | បន្ទាយមានជ័យ | 80,925.00 | 268 | 215 | 4 | 1 | 1 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សរុប (II) | | 492,635.60 | 1 719 | 1 534 | 63 | 26 | 13 |
| III. **ការងារឥណទានគ្រប់គ្រងដោយសហគមន៍** | | | | | | | |
| ១ | ស្វាយរៀង | 126,877.00 | 704 | 413 | 45 | 5 | 1 |
| ២ | កំពង់ចាម (ស្រុកបាធាយ) | គ្មានរបាយការណ៍ | - | - | - | - | - |
| សរុប (III) | | 126,877.00 | 704 | 413 | 45 | 5 | 1 |
| **សរុបរួម (I,II,III)** | | **998,973.23** | **3 123** | **2 505** | **179** | **66** | **30** |

- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងឥណទានជនបទ ចំនួន ៤ លើក នៅខេត្តកំពត ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ។
- បានចុះពិនិត្យ គាំទ្រ និងតាមដានដំណើរការបណ្តុះបណ្តាលសហគមន៍សន្សំប្រាក់ចំនួន ០១ វគ្គ នៅភូមិអាឡែង ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុប ២៤ នាក់ ស្ត្រី ១២ នាក់។
- បានរៀបចំសិក្ខាសាលាស្តីពីការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហា ប្រឈម របស់សហគមន៍សន្សំប្រាក់ នៅខេត្តកំពង់ចាម ដែលមានសិក្ខាកាមមកពីមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត ទាំង ២៥ និងសមាជិកសហគមន៍សន្សំប្រាក់មកពីខេត្តមួយចំនួន សរុបប្រមាណ ៥៥ នាក់ ស្ត្រី ១០ នាក់។
- បានរៀបចំសិក្ខាសាលាស្តីពី ការបូកសរុបលទ្ធផលប្រចាំឆ្នាំលើការងារឥណទានជនបទ ចំនួន ០១ លើក នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប មានសិក្ខាកាមចូលរួមសរុបចំនួន ៥០ នាក់ ស្រី ១៤ នាក់។
- បានរៀបចំអង្គវិប្បសនាប្រចាំឆ្នាំសម្រាប់ការងារឥណទានជនបទ នៅខេត្តព្រះសីហនុ ដែលមានអង្គវិប្បសនាចំនួន ៧០ នាក់។

### ២.១.៣ ការងារសហគ្រាសខ្នាតតូច

- បានចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងសិប្បកម្មផលិតសាប៊ូ ចំនួន ២ លើក នៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ។
- បានចុះបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូ ចំនួន ៦ វគ្គ នៅខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុប ១២០ នាក់ ស្ត្រី ៥៩ នាក់។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច នៅភូមិត្បែង ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០១ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៣១ នាក់ ស្រី ១៤ នាក់ ។
- បានចុះបណ្តុះបណ្តាល និងការធ្វើសិប្បកម្មផលិតសាប៊ូ ចំនួន ៦ វគ្គ នៅខេត្តកំពង់ធំ និងខេត្តសៀមរាប មានសិក្ខាកាមចូលរួមសរុប ១២០នាក់ ស្ត្រី ៦៤ នាក់។

- បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៣១ នាក់ ស្រី ១៧ នាក់ នៅខេត្តតាកែវ។

### ២.១.៤ ការងាររកទីផ្សារ

- បានចុះសិក្សា និងរៀបចំទីតាំងសម្រាប់ការតាំងពិព័រណ៌ផលិតផលជនបទ នៅខេត្តស្វាយរៀង។
- បានចុះរៀបចំតាំងពិព័រណ៌ផលិតផលជនបទ ក្រោមប្រធានបទ "ភូមិខ្ញុំផលិតផលខ្ញុំ" នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង ដោយមានតាំងបង្ហាញស្តង់ចំនួន ៣០ និងមានអ្នកចូលរួមទស្សនាពិព័ណ៌សរុបប្រមាណជាង ២ ០០០ នាក់។
- បានរៀបចំសិក្ខាសាលាស្តីពីការពិគ្រោះយោបល់ ផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមរបស់ទីផ្សារផលិតផលជនបទ នៅខេត្តតាកែវ ចំនួន ១ លើក មានសិក្ខាកាមចូលរួម ៣១ នាក់ ស្រី ១៨ នាក់។
- បានរៀបចំសិក្ខាសាលាស្តីពីការចែករំលែកការយល់ដឹង និងផ្សព្វផ្សាយពីផលិតផលសម្រេច នៅខេត្តកំពត ចំនួន ០១លើក មានសិក្ខាកាមចូលរួមចំនួន ៣១ នាក់ ស្រី ២០ នាក់។
- បានបន្តការងារសាងសង់ផ្សារជនបទដំហ៊ាន ២ នៅស្រុករុក្ខគិរី ខេត្តបាត់ដំបង ដែលផ្សារនេះគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២៣ ។

## ២.២ លទ្ធផលដោយថវិកាដៃគូ

### ២.២.១ គម្រោងបំពេញបន្ថែមលើគម្រោងសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន

- **សាងសង់បង្គន់អនាម័យ៖** បានសាងសង់បង្គន់អនាម័យបានចំនួន ១០០ បង្គន់ សម្រាប់ប្រជាពលរដ្ឋចំនួនបីភូមិនៅក្នុងឃុំ ស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល។
- **ការងារជួសជុលគេហដ្ឋានជូនប្រជាពលរដ្ឋ៖**បានជួសជុលផ្ទះជូនប្រជាពលរដ្ឋក្រីក្របានចំនួន ១០០ ខ្នងផ្ទះ សម្រាប់ប្រជាពលរដ្ឋចំនួនបី ភូមិនៅក្នុងឃុំ ស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល។
- **ការងារតបណ្តាញអគ្គិសនីជូនប្រជាពលរដ្ឋ៖** បានទិញសម្ភារអគ្គិសនី និងទំនាក់ទំនងភ្ជាប់បណ្តាញចូលផ្ទះជូនប្រជាពលរដ្ឋក្រីក្របានចំនួន ៧០ ខ្នងផ្ទះ សម្រាប់ប្រជាពលរដ្ឋចំនួនបីភូមិនៅក្នុងឃុំ ស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល។
- **ការងារបង្កើតសហគមន៍បណ្តុះផ្សិត៖** បានសាងសង់រោង លាយល្បាយសម្រាប់ការវិចខ្ចប់ធ្វើជាកញ្ចប់បណ្តុះផ្សិតចំនួន ០២ ខ្នង ដោយនីមួយៗមានទំហំ ៦ម x ១២ម និងបានបំពាក់នូវឧបករណ៍ ព្រមទាំងវត្ថុធាតុដើមសម្រាប់ធ្វើកញ្ចប់ផ្សិត រួមមាន ម៉ាស៊ីនរ៉ែងអាចម៍រណា ម៉ាស៊ីនវិចខ្ចប់អាចម៍រណា ធ្នើសម្រាប់ដាក់ផ្ទុកកញ្ចប់ផ្សិត ទូស្ទីម និងឡចំហុយកញ្ចប់ផ្សិត និងបានចុះចងក្រងក្រុមប្រជាពលរដ្ឋជាសហគមន៍ផលិតកញ្ចប់ផ្សិត និងបណ្តុះ ផ្សិត។

### ២.២.២ គម្រោងពិពិធកកម្មសេដ្ឋកិច្ចជនបទ សម្រាប់កសិករដែលមានចំណូលទាប នៅស្រុកគីរីវង់ ខេត្តតាកែវ

- **សាងសង់រោងស្តុកបន្លែ និងជង្រុកស្រូវ៖** បានសាងសង់រោងស្តុកបន្លែចំនួន ០៣ រោង មានទំហំ ៦ម x ១០ម ដោយធ្វើធ្នើដាក់បន្លែចំនួន៤ គ្រឿង សម្រាប់សហគមន៍ភូមិបីមានជ័យ ឃុំគិរីចុង

កោះ  សហគមន៍ទំនប់អាងស្រែកែស ឃុំសោម និងសហគមន៍ពឹងពង់សុខសែនជ័យ ឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ និងបានសាងសង់រោងជម្រុកស្រូវចំនួនមួយទំហំ ១០មx២៤ម នៅសហគមន៍គិរីឧត្តម្តតាអូរ ឃុំតាអូរ ស្រុកគិរីវង់ខេត្តតាកែវ។

- **ទិញត្រាក់ទ័រផ្គត់ផ្គង់សហគមន៍៖** បានទិញត្រាក់ទ័រម៉ាកចនឌាចំនួន ០១ គ្រឿង កំលាំង ៥៥ សេស និងគ្រឿងបង្គុំ ដូចជារនាស់ផាល និងអង្គប់ជូនសហគមន៍ ,គិរីឧត្តមតាអូរ ឃុំតាអូរ ស្រុកគិរីវង់ ខេត្តតាកែវ។
- **ទិញជីផ្គត់ផ្គង់សហគមន៍៖** បានទិញជីគ្រាប់ចំនួន ៧៨០ បាវ ក្នុងនោះជីគីមីចំនួន ១៨០ បាវ និងជីសរីរាង្គចំនួន ៦០០ បាវ ព្រមទាំងជីសរីរាង្គប្រភេទជីទឹកចំនួន ១០ កេះ ស្មើ ១២០ ដប ជូនសហគមន៍ ភូមិបីមានជ័យ ឃុំគិរីចុងកោះ ស្រុកគិរីវង់ខេត្តតាកែវ។

**២.២.៣ គម្រោងចែកចាយទឹកស្អាត ដើម្បីអនាគតទាំងអស់គ្នា ខេត្តតាកែវ**

- **ការងារតបណ្តាញទឹកស្អាត៖** គម្រោងបានផ្តល់ទុយោ និងការតភ្ជាប់បណ្តាញទឹកស្អាតព្រមទាំងកាយជីកកប់ទុយោចំនួន ៣១ ៥០០ ម និងសម្ភារៈដំណរភ្ជាប់ដូចជា វ៉ានសុង ,តេ ,កែង , ជាដើម សម្រាប់តភ្ជាប់បណ្តាញជូនសហគមន៍ទាំង ៤ ឲ្យទៅជាសម្ព័ន្ធក្នុងនោះមានសហគមន៍ភូមិបីមានជ័យ ឃុំគិរីចុងកោះ សហគមន៍ទំនប់អាងស្រែកែស ឃុំសោម សហគមន៍ពឹងពង់សុខសែនជ័យ ឃុំសោម និងសហគមន៍គិរីឧត្តម្តតាអូរ ឃុំតាអូរ ដែលសហគមន៍ទាំង ៤ ស្ថិតក្នុងស្រុកគិរីវង់ ខេត្តតាកែវ។
- **ការផ្តល់កុំព្យូទ័រ៖** បានផ្តល់កុំព្យូទ័រចំនួន ៤ គ្រឿង និងព្រីនធ័រចំនួន ៤ គ្រឿងជូនដល់សហគមន៍ទាំង ៤។

  **បើកវគ្គបណ្តុះបណ្តាល៖** បានបើកវគ្គបណ្តុះបណ្តាលស្តីពី**ការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីបង្កើនប្រាក់ចំណូល** ចំនួន ១០ វគ្គ នៅឃុំគិរីចុងកោះ ឃុំសោម ឃុំតាអូរ ឃុំព្រៃរំដេង និងឃុំព្រៃអំពក ក្នុងស្រុកគិរីវង់ ខេត្តតាកែវ និងបានបើកវគ្គបណ្តុះបណ្តាលកុំព្យូទ័រ ចំនួន ៤ វគ្គ ជូនគណកម្មាធិការសហគមន៍។

## ៣. បញ្ហាប្រឈម

- ការរៀបចំសកម្មភាពនានានៅមិនទាន់សមស្របតាមការអនុវត្តការងារក្នុងបរិបទប្រក្រតីភាពនៃគន្លងរស់នៅថ្មីជាមួយនឹងកូវីដ-១៩ ។
- ទាំងគោលនយោបាយ ទាំងសកម្មភាពនៅពុំទាន់ទាក់ទាញ ដែលបណ្តាលឲ្យថវិកាវិនិយោគនៅមានកម្រិត។
- ប្រជាកសិករ និងផលិតករ សិប្បករមិនទាន់ចងក្រងគ្នាជាសហករណ៍ (Cooperatives) នៅតែមានទស្សនពឹងផ្អែកលើជំនួយពីខាងក្រៅ។
- ដៃគូនិងអង្គការធ្លាប់សហការនៅតាមបណ្តាខេត្តមួយចំនួន បានបញ្ចប់បេសកកម្ម ដែលនាំបន្ទុកមួយចំនួនបន្ថែមទៀតដល់នាយកដ្ឋាន។

## ៤. ទិសដៅអនុវត្តបន្ត

- បន្តពង្រឹង និងពង្រីកគម្រោងឥណទានទៅតាមបណ្តាខេត្តផ្សេងៗ។

- ជំរុញដំណើរការគាំទ្រសហគមន៍សន្សំប្រាក់នៅតាមបណ្តារាជធានី ខេត្ត និងពង្រឹងសមត្ថភាពដល់មន្ត្រីក្នុងការគ្រប់គ្រង។
- ជំរុញការងារអភិវឌ្ឍន៍ផ្សារជនបទនៅតាមបណ្តាខេត្តគោលដៅ។
- បន្តចុះពិនិត្យ និងវាយតម្លៃគម្រោងឥណទានជនបទតាមបណ្តារាជធានី ខេត្តតាមផែនការគ្រោងទុក។
- ជំរុញការផ្តល់ឥណទាន និងប្រមូលត្រឡប់មកវិញឲ្យបានក្នុងកម្រិតអតិបរមាសម្រាប់ខេត្តគោលដៅដែលគ្រប់គ្រងផ្ទាល់ និងបង្កើនកិច្ចសហការជាមួយអង្គការដៃគូ។
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច។
- ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម។
- បន្តរៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តិតាមវិស័យ ដូចជាឥណទានជនបទ សហគ្រាសខ្នាតតូច និងរកទីផ្សារសម្រាប់ផលិតផលជនបទ។
- បន្តបង្កើនកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបើកវគ្គនៅនឹងកន្លែង ការបញ្ជូនមន្ត្រីឲ្យទៅចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា ការផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីនាយកដ្ឋានជាមួយនឹង មន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងស្ថាប័នផ្សេងៗ និងលើកទឹកចិត្តឲ្យមន្ត្រីសិក្សាស្រាវជ្រាវពីចំណេះដឹងថ្មីៗបន្ថែមដោយខ្លួនឯង។
- ពង្រឹងការតាមដាន និងវាយតម្លៃ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងារ។

## ៥. សេចក្តីសន្និដ្ឋាន

ការអភិវឌ្ឍសេដ្ឋកិច្ចជនបទជាការរួមចំណែកមួយដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ដែលក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទបានផ្តល់ជូនប្រជាជននូវការបណ្តុះបណ្តាលអំពីបំណិនជីវិត ពង្រឹង និងពង្រីកមុខរបរបង្កើនប្រាក់ចំណូលបន្ថែម ទីផ្សារកាន់តែទូលំទូលាយ និងទទួលបានដើមទុនពីកម្ចីដែលមានអត្រាការប្រាក់ទាបសមរម្យ ជំរុញសកម្មភាព សេដ្ឋកិច្ចនៅតំបន់ជនបទឲ្យមានការកើនឡើងជាបន្តបន្ទាប់។

**ប្រធាននាយកដ្ឋាន**

**ចម្លងជូនៈ**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអគ្គនាយកបច្ចេកទេស
- ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ
  "ដើម្បីគោរពជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ